**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :........០៤២/២៣..................**ក.ប**/ស.ណ.ន.ខ.ល

# សេចក្តីណែនាំ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនម្ចាស់ ឬនាយករោងចក្រ សហគ្រាស គ្រឹះស្ថានទាំងអស់ ស្ថិតក្នុងដែនអនុវត្តនៃច្បាប់ស្តីពីការងារឱ្យបានជ្រាបថា ដើម្បីបង្កលក្ខណៈងាយស្រួលដល់បងប្អូនកម្មករនិយោជិតក្នុងការទទួលបានព័ត៌មានត្រឹមត្រូវ និងឆាប់រហ័ស ជាពិសេសគោលនយោបាយ និងវិធានការនានារបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលផ្តល់អត្ថប្រយោជន៍ដល់បងប្អូនកម្មករនិយោជិត ម្ចាស់ ឬនាយករោងចក្រ សហគ្រាស គ្រឹះស្ថាន ត្រូវផ្សព្វផ្សាយ លើកទឹកចិត្ត និងណែនាំដល់បងប្អូនកម្មករនិយោជិតអំពីរបៀបប្រើប្រាស់ និងការតភ្ជាប់តេឡេក្រាមរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដូចខាងក្រោម៖

ក. **ករណីដែលមានប្រើប្រាស់កម្មវិធីតេឡេក្រាមស្រាប់**

១. សូមស្កេន QR Code

@SPMHUNSEN

២. សូមស្វែងរកឈ្មោះ **@spmhunsen** ឬ **Prime Minister HUN SEN** ហើយចុចភ្ជាប់ (JOIN)

៣. សូមចុចតំណភ្ជាប់ https://t.me/spmhunsen

ខ. **ករណីដែលមិនទាន់មានប្រើប្រាស់កម្មវិធីតេឡេក្រាម សូមស្កេន QR Code ខាងក្រោម ដើម្បីទាញយកឯកសារស្តីពីរបៀបប្រើប្រាស់កម្មវិធីតេឡេក្រាម និងរបៀបតភ្ជាប់ទៅតេឡេក្រាម៖**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានក្តីសង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ ឬនាយករោងចក្រ សហគ្រាស គ្រឹះស្ថាន និងបងប្អូនកម្មករនិយោជិតទាំងអស់ នឹងអនុវត្តតាមសេចក្តីណែនាំនេះប្រកបដោយប្រសិទ្ធភាព។

ថ្ងៃ ពុធ ៤កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០២៣

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន**:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ

*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩*